**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានឃោធសេវា**
**នាយកដ្ឋានព័ត៌មាន**
លេខ:...............

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត ឡាវ **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាត នៃព្រះរា ជាណាចក្រកម្ពុជា** អមដំណើរដោយប្រធាន ADSOM ព្រមទាំងមន្ត្រីការពារជាតិមួយចំនួនទៀត អញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានក្រៅផ្លូវការ (Asean Defence Ministers Meeting "ADMM" Retreat ) ដែលនឹងប្រព្រឹត្តិទៅពីថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ។

ADMM ក្រៅផ្លូវការនឹងធ្វើជាវេទិការសម្រាប់រដ្ឋមន្ត្រីការពារជាតិអាស៊ានធ្វើការប្រជុំ និងពិភាក្សាអំពីបញ្ហាការពារជាតិ និងសន្តិសុខក្នុងតំបន់ដើម្បីដោះស្រាយរួមគ្នាចំពោះភាពប្រឈមសន្តិសុខ និងដើម្បីលើកកម្ពស់សន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពចំពោះសហគមន៍ និងប្រជាជនអាស៊ានស្របតាមទិសស្លោក ADMM ២០១៦ "ការពង្រឹងកិច្ចសហប្រតិបត្តិការការពារជាតិសម្រាប់សហគមន៍អាស៊ានប្រកបដោយភាពរឹងមាំ" ។

កិច្ចប្រជុំ ADMM ក្រៅផ្លូវការពេលនេះ ក៏ជាឱកាសធ្វើជាសាក្សីនៃការផ្ទេរប្រគល់ប្រធាន ADMM ប្តូរវេនមួយឆ្នាំម្តងពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ជូនសាធារណរដ្ឋហ្វីលីពីនផងដែរ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ខែវិច្ឆិកា ឆ្នាំ២០១៦